**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៣៩២ ព.ណ.ភ.ព..

ថ្ងៃអង្គារ ១រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

ក្នុងនាមគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំនិងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា ដោយទទួលបានជោគជ័យជាបន្តបន្ទាប់ក្នុងការរៀបចំនិងចូលរួមពិព័រណ៍ចិន-អាស៊ានចំនួន២២លើកក្នុងពេលកន្លងទៅ ក្រសួងពាណិជ្ជកម្មនឹងបន្តចូលរួមរៀបចំ "ពិព័រណ៍ចិន-អាស៊ានលើកទី២៣ (The 23rd China-ASEAN Expo)" ដែលនឹងរៀបចំដោយគណៈកម្មការរៀបចំពិព័រណ៍ចិន-អាស៊ានពីថ្ងៃទី១៧-២១ ខែកញ្ញា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍អន្តរជាតិទីក្រុងណាននីង តំបន់ស្វយ័តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន។

ពិព័រណ៍ចិន-អាស៊ាន គឺជាវេទិកានៃការផ្លាស់ប្តូរពាណិជ្ជកម្ម និងវិនិយោគដ៏សំខាន់រវាងបណ្តាប្រទេសជាសមាជិកអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន។ ដើម្បីបន្តជំរុញសកម្មភាពពាណិជ្ជកម្ម និងវិនិយោគរវាងកម្ពុជា និងចិនឱ្យដល់គោលដៅដែលរដ្ឋាភិបាលនៃប្រទេសទាំងពីរបានកំណត់ ក្រសួងពាណិជ្ជកម្មក្នុងនាមដៃគូសហការរៀបចំ សូមអញ្ជើញធុរជន សហគ្រិន វិនិយោគិន ផលិតករកម្ពុជា និងសាធារណជនទូទៅ ដែលមានបំណងចូលរួមតាំងបង្ហាញ/លក់ផលិតផល/សេវាកម្ម និងចាប់ដៃគូពាណិជ្ជកម្មជាមួយពាណិជ្ជករចិន និងអាស៊ាន សូមរៀបចំដាក់ពាក្យចូលរួមពិព័រណ៍ខាងលើ និងព្រឹត្តិការណ៍អមផ្សេងៗតាមរយៈ QR Code ខាងក្រោម ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦។

សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទំនាក់ទំនងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ +៨៥៥ ៨៩ ៩១១ ១០១ / +៨៥៥ ១៧ ៧៥៩ ៥៦៧ / +៨៥៥ ៨៧ ៧៥៥ ៥៥១ ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦ ឬអ៊ីម៉ែល៖ san.phirun@moc.gov.kh / meas.vanna@moc.gov.kh / tong.rita@moc.gov.kh។/.

**សូមអរគុណ!**

https://go.gov.kh/moc/cncmh1
GO.gov.kh

# KINGDOM OF CAMBODIA

**Nation - Religion - King**

**Ministry of Commerce**

N° 0392 MOC. Đ /EA

Phnom Penh, 3 February 2026

## ANNOUNCEMENT

On behalf of the Inter-Ministerial Committee for Participation in the World Expositions and International Trade Fairs, the Ministry of Commerce has the honor to inform all traders and the public that, following Cambodia's successful participation in the China-ASEAN Expo (CAEXPO) for 22 consecutive editions, the Ministry of Commerce in collaboration with the CAEXPO Secretariat, is going to organize **"the 23rd China-ASEAN Expo"**, to be held from 17-21 September 2026 in Nanning, Guangxi Zhuang Autonomous Region, People's Republic of China.

The China-ASEAN Expo is a significant platform for business exchange and investment cooperation between ASEAN member states and China. To continue promoting business and investment activities between Cambodia and China, aiming to realize the target set by both governments, the Ministry of Commerce, as a co-organizer, would like to cordially invite all Cambodian businessmen, entrepreneurs, investors, producers, and the public who are interested to showcase the products/services and to forge business partnerships with Chinese and ASEAN counterparts, please kindly fill and submit the application form to the Ministry of Commerce via the below QR Code by **30 June 2026**.

For further information, please contact the Department of Exhibition Affairs, General Directorate Trade Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, or officials in charge via:
Tel: +855 89 911 101 / +855 17 759 567 / +855 87 755 551
MOC Call Center: 1266
E-mail: san.phirun@moc.gov.kh / meas.vanna@moc.gov.kh / tong.rita@moc.gov.kh.

https://go.gov.kh/moc/cncmh1

GO.gov.KH

THANK YOU!